ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ នាមនាមប្រជារាស្ត្រខ្មែរ

លេខ : ០៧ តុលាការកំពូល

ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥

សាលដីកា

លេខ : ៥៦

ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | ជីវ កេង | ចៅក្រម |
| ៤- លោក | ប្រាក់ គឹមសាន | ចៅក្រមរបាយការណ៍ |
| ៥- លោក | ប៉ែន សារឿន | ចៅក្រម |

ក្រឡាបញ្ជី

លោក ឈាង វិន្ថា

តំណាងមហាអយ្យការ

**ឯកឧត្តម ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ៨២"ង" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ០៧ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

***ពិរុទ្ធ*** : ក្លែងបន្លំប្រើប្រាស់លិខិតឯកជន ប្រព្រឹត្តកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០២ នៅក្រុងភ្នំពេញ ។

-ជនជាប់ចោទឈ្មោះអេង ប៊ុងឃាង ( ម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិល្វាកោង ឃុំកំពង់ក្រាំង ស្រុកពារាំង ខេត្តព្រៃវែង ។ ទីលំនៅសព្វថ្ងៃផ្ទះលេខ៤១E₀ សង្កាត់ទួលស្វាយព្រៃទី១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះលន់ អេង "ស" ម្តាយឈ្មោះសុខ ស៊ីម "ស" ប្តីឈ្មោះនាង សេង មានកូន០៣នាក់ ទោសពីមុនគ្មាន ។ ឃុំខ្លួនថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៤ ។

-មានមេធាវី : លោក ហុង គឹមសួន

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះហេង ទុយ (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ៣០E₀ សង្កាត់ផ្សារថ្មី១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

-មានមេធាវី : លោក ជាត់ ពៅស៊ាង

-តាមពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះហេង ទុយ បានប្តឹងពីឈ្មោះ អេង ប៊ុនឃាង ភេទស្រី អាយុ៤៨ឆ្នាំ ពីបទក្លែងស្នាមមេដៃលើកិច្ចសន្យា ចុះថ្ងៃទី៣១១០-១៩៩៨ ។

-បានឃើញដីកាឃុំខ្លួនអ្នកស្រីអេង ប៊ុនឃាង លេខ៤៨៦១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៤ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៦"ឃ"ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤របស់លោកហុង គីមសួរ ជាមេធាវីការពារអោយអ្នកស្រី អេង ប៊ុងឃាង ប្តឹងមិនសុខចិត្តនឹងដីកាឃុំខ្លួនលេខ៤៨៦១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៤ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើដីកាសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា : រឿងក្តីនេះ ការស៊ើបអង្កេតបានចប់សព្វគ្រប់ហើយ ដោយមហាអយ្យការបានចោទប្រកាន់ជនជាប់ចោទពីបទក្លែង និង ប្រើប្រាស់លិខិតក្លែងតាមមាត្រា៥០ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឃើញថាជាបទល្មើសមជ្ឈិម ។ តែជនជាប់ចោទមានជំងឺដែលមានវិញ្ញាប័នត្រពិនិត្យរោគ ឃើញគ្រុនពោះវៀន សំពាធឈាមឡើងខ្ពស់ ស្វិតជើងទាំងពីរដើរពុំរួច ដែលគួរសាលាឧទ្ធរណ៍ពិចារណា ។ ម្យ៉ាងទៀតគ្មានអ្វីបញ្ជាក់ថា ជនជាប់ចោទគេចវេស ឬ គៀបសង្កត់សាក្សី ដែលនាំអោយលំបាកអង្កេតដែរ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៨២"ង"ចុះថ្ងៃទី២០ ខែកញ្ញាឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤របស់ឈ្មោះហុង គីមសួរ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តំកល់ដីកាសំរេចលេខ៤៨៦១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៤ របស់ចៅក្រមស៊ើប អង្កេតតុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១៥០ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៤ របស់លោកហុង គីមសួរ ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះអេង ប៊ុនឃាង ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៨២"ង" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥ របស់ឈ្មោះឈាង ប៊ុនឃាង ។

-បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ របស់ឈ្មោះហេង ទុយ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា :

+ដោយជនល្មើសមានមុខរបរ មានគ្រួសារ និង មានអាស័យដ្ឋានពិតប្រាកដ ។

+អំពើល្មើសជាបទមជ្ឈិម

+ជនល្មើសមានជំងឺជាប្រចាំ

+ការស៊ើបអង្កេតបានចប់សព្វគ្រប់ហើយ

+គប្បីតុលាការពិចារណាអោយជនជាប់ចោទនៅក្រៅឃុំជាបណ្តោះអាសន្ន ។

+បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៨២"ង" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។

-បានស្តាប់ក្រឡាបញ្ជីអានសារណា របស់ជនជាប់ចោទឈ្មោះអេង ប៊ុងឃាង (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

-បានស្តាប់ក្រឡាបញ្ជីអានសារណាតប របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះហេង ទុយ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកហុង គឹមសួន ជាមេធាវីការពារអោយជនជាប់ចោទ នៅពេលជំនុំជំរះថា : ការធ្វើកោសល្យវិច្ឆ័យនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ របស់ការិយាល័យកោសល្យវិច្ឆ័យ នៃក្រសួងមហាផ្ទៃ បានចេញលទ្ធផលបញ្ជាក់យ៉ាងច្បាស់ថាស្នាមក្រយៅដៃសរសេរឈ្មោះហេង ទុយ ដែលថតចេញពីកិច្ចសន្យា ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៨ មានចំណុចពិសេសដូចគ្នានឹងស្នាមក្រយៅចង្អុលដៃស្តាំរបស់ឈ្មោះប៊ុន ច័ន្ទគ្រីស្នា ហៅ ជាវិទ្ធីយ៉ា មិនមែនស្នាមមេដៃរបស់ជនជាប់ចោទឈ្មោះអេង ប៊ុនឃាង ទេ ។ សាលាឧទ្ធរណ៍បានជំនុំជំរះដល់អង្គសេចក្តីដោយបានសំរេចដោះលែងកូនក្តីរបស់ខ្លួនរួចហើយដែរ ដូច្នេះសូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមសាលដីកាសាលាឧទ្ធរណ៍ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា : សុំអោយនៅក្រៅឃុំ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៥០ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៤ របស់លោកហុង គឹមសួន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូចចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញដែរ ដែលសំរេចឃុំខ្លួនឈ្មោះអេង ប៊ុនឃាង ជាបណ្តោះអាសន្ន ដោយអាងហេតុថា ខ្លាចជនជាប់ចោទគេចខ្លួន មិនព្រមចូលមកតុលាការ និង ខ្លាចជនជាប់ចោទមានឥទ្ធិពលលើសាក្សី នោះគឺជាការភ័ន្តច្រឡំ ពីព្រោះថា :

+ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទមជ្ឈិម

+ជនជាប់ចោទមានមុខរបរ មានគ្រួសារ និង មានទីលំនៅពិតប្រាកដ

+ការស៊ើបអង្កេតបានចប់សព្វគ្រប់ហើយ

+ជនជាប់ចោទមានជម្ងឺជាប្រចាំ

ដូច្នេះតាមមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ជនជាប់ចោទអាចត្រូវសំរេចឱ្យនៅក្រៅឃុំបណ្តោះអាសន្នបាន ។

-យល់ឃើញថា តុលាការកំពូលបានកោះហៅជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីហើយ ប៉ុន្តែសាម៉ីខ្លួនពុំបានមកចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៨២"ង" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

***វិនិច្ឆ័យសេចក្តីកំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី***

***ប៉ុន្តែចាត់ទុកជាចំពោះមុខ***

១-ទទួលបណ្តឹងសាទុក្ខលេខ១៥០ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៤ របស់លោកហុង គីមសួន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ៨២"ង" ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទាំងមូល ដោយឥតបង្វិល ។

៣-បង្គាប់ឱ្យដោះលែងឈ្មោះអេង ប៊ុនឃាង ពីមន្ទីរឃុំឃាំងជាបន្ទាន់ ប្រសិនបើឈ្មោះនេះពុំមានជាប់ពីបទផ្សេងទៀតទេ ។

៤-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ០៧ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៤ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីបញ្ចូលក្នុងរឿងអង្គសេចក្តី ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥ ។៕